ធនាគារជាតិ នៃ កម្ពុជា
ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

ថ្ងៃ ចន្ទ ២ រោច ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ កក្កដា ឆ្នាំ២០២៤

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# កិច្ចប្រជុំទ្វេភាគី និង
# ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់
# រវាង ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលទីម័រខាងកើត

នៅថ្ងៃចន្ទ ២រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា** និង **ឯកឧត្តម Hélder Lopes ទេសាភិបាល ធនាគារកណ្តាលទីម័រខាងកើត** បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំទ្វេភាគី និងចុះហត្ថលេខាលើអនុស្សរណៈយោគយល់ នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា។

កិច្ចប្រជុំទ្វេភាគីនេះគឺជាកិច្ចប្រជុំលើកដំបូងរវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលទីម័រខាងកើត ដែលបានបង្ហាញពីការចាប់ផ្តើមនៃកិច្ចសហប្រតិបត្តិការនិងចំណងមិត្តភាពយ៉ាងជិតស្និទ្ធ ក្នុងគោលដៅរួមចំណែកអភិវឌ្ឍវិស័យធនាគារនៃប្រទេសទាំងពីរឱ្យកាន់តែរីកចម្រើនថែមទៀត។ ក្នុងស្មារតីនៃកិច្ចសហប្រតិបត្តិការល្អប្រសើរ ថ្នាក់ដឹកនាំនៃធនាគារកណ្តាលទាំងពីរបានពិភាក្សា និងផ្លាស់ប្តូរយោបល់លើស្ថានភាពសេដ្ឋកិច្ច នយោបាយរូបិយវត្ថុ និងដំណើរការវិវត្តនៃវិស័យធនាគារនៃប្រទេសទាំងពីរ ជាពិសេសផ្តោតលើការចែករំលែកនូវបទពិសោធន៍ និងយុទ្ធសាស្ត្រនៃការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ ដុល្លារូបនីយកម្ម ក៏ដូចជាប្រធានបទសំខាន់ៗផ្សេងទៀត ដែលមានអត្ថប្រយោជន៍សម្រាប់ធនាគារកណ្តាល និងប្រទេសទាំងពីរ។

នាឱកាសនោះដែរ ទេសាភិបាលនៃធនាគារកណ្តាលទាំងពីរបានអញ្ជើញចុះហត្ថលេខាលើអនុស្សរណៈយោគយល់ដែលមានគោលបំណងពង្រឹងកិច្ចសហការលើ៖ i/- ប្រតិបត្តិការធនាគារកណ្តាល ii/- ការតភ្ជាប់ការទូទាត់សងប្រាក់ iii/- នវានុវត្តន៍ហិរញ្ញវត្ថុឌីជីថល iv/- ការត្រួតពិនិត្យធនាគារ v/- បរិយាបន្នហិរញ្ញវត្ថុ និង vi/- ការអភិវឌ្ឍធនធានមនុស្ស។ តាមរយៈអនុស្សរណៈយោគយល់នេះ មន្ត្រីជំនាញនៃធនាគារកណ្តាលទាំងពីរនឹងពង្រឹងកិច្ចសហប្រតិបត្តិការបច្ចេកទេសកាន់តែរឹងមាំ តាមរយៈកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់ជាប្រចាំ ការចែករំលែកព័ត៌មាននិងទិន្នន័យពាក់ព័ន្ធនឹងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបទពិសោធន៍និងចំណេះដឹងលើការងារបច្ចេកទេស ជាដើម។

ថ្នាក់ដឹកនាំនៃធនាគារកណ្តាលទាំងពីរបានវាយតម្លៃខ្ពស់ចំពោះលទ្ធផលនៃកិច្ចប្រជុំខាងលើ និងបានសម្រេចឱ្យមានកិច្ចប្រជុំជាប្រចាំឆ្នាំ ព្រមទាំងបានប្តេជ្ញាបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការនេះឱ្យកាន់តែរឹងមាំនិងទទួលបានលទ្ធផលផ្លែផ្កាជាទីមោទនៈ។

**ទំនាក់ទំនង ៖**
អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh
**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.gov.kh, www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA